# សិលាចារឹកប្រាសាទខ្នារ K.1312

ប្រាសាទខ្នារ មានទីតាំងស្ថិតនៅក្នុងភូមិក្រឡាពាស ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ ប្រាសាទនេះកសាងឡើងដើម្បីឧទ្ទិសដល់ទេពក្នុងព្រហ្មញ្ញសាសនា ជាពិសេស គឺព្រះវិស្ណុ ព្រោះយើងឃើញមានដូចជា ព្រះត្រិវិក្រម សកវ្រាហ្មណា។ ប្រាសាទនេះកសាងដំបូងក្នុងកំឡុងរាជព្រះបាទជ័យវរ្ម័នទី៤ ព្រះបាទហស៌វរ្ម័នទី២ ព្រះបាទជ័យវរ្ម័នទី៥ ព្រះបាទសូរ្យវរ្ម័នទី១។ ដោយហេតុថាប្រាសាទនេះកសាងឡើងច្រើនដំណាក់កាល ម៉្លោះហើយសិលចារឹកនៅប្រាសាទនេះក៏មានច្រើនផ្ទាំងដូចគ្នាដែរ។ នៅក្នុងឆ្នាំ១៩៦៦ លោក ហ្សក សឺដេស បានចុះបញ្ជីសិលាចារឹកសរុបនៅប្រាសាទនេះចំនួន ៤ ផ្ទាំង រួមមាន K.355, K.356, K.660, K.661 ប៉ុន្តែក្នុងពេលនោះលោកមានចន្លោះដោយសារពុំបានចុះបញ្ជីសិលាចារឹកចំនួន១ ទើបនៅពេលពេលក្រោយមក គេបានចុះបញ្ជីសិលាចារឹកមួយទៀតបន្ថែម គឺ K.1312។

ជាសង្ខេបខ្លីមក សិលាចារឹកប្រាសាទខ្នារ K.1312 ចារឹកនៅឆ្នាំ ៨៩១ នៃមហាសករាជ ត្រូវនឹងឆ្នាំ ៩៦៩ នៃគ្រឹស្តសករាជ ចំនឹងថ្ងៃ ៤រោច ខែស្រាពណ៍ ថ្ងៃសៅរ៍ ដែលរៀបរាប់អំពីព្រាហ្មណ៍ម្នាក់ឈ្មោះថា "ណិវន្តចារ្យ" មានឋានន្តរនាមថា "ម្រតេញ" ដែលជាអធិការបតីនៅភ្នំកម្រតេងជគតលិង្គបុរ។ "ភ្នំកម្រតេងជគតលិង្គបុរ" ឬ "ភ្នំកម្រតេងជគតតរាជ្យ" សំដៅដល់មហាប្រាសាទធំនៅតំបន់កោះកេរសព្វថ្ងៃនេះឯង។ គេបានអញ្ជើញព្រាហ្មណ៍ "ណិវន្តចារ្យ" មកទេវស្ថាននេះដើម្បីឱ្យលោកបង្កើតមូលនិធិបន្ថែមដើម្បីជួយផ្គត់ផ្គង់ដល់ទេវស្ថាន ដូចជា ការជាវដីធ្លីជាដើម ហើយបានកំណត់ព្រំប្រទល់ដីយ៉ាងជាក់លាក់ថែមទៀតផង។

នៅក្នុងសិលាចារឹកនេះក៏បានផ្តល់ទិន្នន័យខាងភាសាសាស្ត្រ និងស្ថាននាមមួយចំនួនឱ្យយើងបានយល់កាន់តែច្បាស់បន្ថែមទៀត ដោយស្ថាននាមទាំងនោះជាភាសាខ្មែរមានដូចជា៖

១. "វ្នំ កម្រតេង៑ ជគត៑ លិង្គបុរ" (ភ្នំកម្រតេងជគតលិង្គបុរ)

២. "វ្រៃ ត្រវង៑ ខ្យប៑" (ព្រៃត្រពាំងខ្យាប់)

៣. "វ្រៃ ចន្ទូរ រំច្យក៑" (ព្រៃចង្ហួរ រំចេក)

៤. "វ្រៃ សស្តា" (ព្រៃសស្តា)

អត្ថបទដោយ៖ កំ វណ្ណារ៉ា

៥. "ឆ្មិង៑ ឆោក ខ្វា" (ស្ទឹងឆោកខ្វា)

៦. "ឆ្មិង៑ ល្យង៑" (ស្ទឹងល្បៀង)

ស្ថាននាមខាងលើនេះ បានបង្ហាញយ៉ាងច្បាស់ដល់ទីតាំងភូមិសាស្ត្ររបស់ប្រទេសកម្ពុជា ដូចជា ជ្រលង ដង អូរ ព្រែក ស្ទឹង រុក្ខជាតិ សត្វ និងបរិស្ថានដែលស្ថិតនៅជុំវិញទីទេវស្ថាននេះ ស្រាប់តែម្តង។

## អត្ថបទពាក្យចារឹក

១. ៨៩១ គក ចតុថី រោចិ គ្រាវន សនេគ្គរវារ ម្រតេញ៑ ណិ

២. វន្តពចាយ៌្យ ខ្ញោញ៑ ន្នំ កម្រតេង៑ ជគត លិង្គបុរ ដោ ភូមិ

៣. ប្រែ ត្រវង៑ ខ្យចិ ណា សង្កតិ តិ ប្វូ៌ ឥស្យ ប្រែ ចន្ទ្វរ វំច្យក៑

៤. ប្រែ សស្តា ឆ្មិង៑ ឆោក ខ្វា ថ្ងៃង៑ ទៅ ល្វះ ត គិ ប្រែ ចស្យ នុវ ឆ្មិង៑ ជារ

៥. ថ្ងៃង៑ ទៅ ល្វះ ត គិ ប្រែ ចស្យ នុវ គ្នង៑ជារ តិ ប្វូ៌ ប្រសប៑ ឆ្មិង៑ ល្យ

៦. ង៑ តី ដោ នុ ភាជន ត វ្រះកម្រតេង៑ អញ៑ តរាជ្យ នុ វ្រះ

៧. កម្រតេង៑ អញ៑ សកវ្រាំហ ង៑ន ភាជន ជ្យង៑ ៧ ថ្ងៃ បូជា វ្រះ

៨. កម្រតេង៑ អញ៑ សុវណ៌្ណ ឱយ្យជ្វ ត វ្រះកម្រតេង៑ អញ៑ តរាជ លិះ

៩. ២ ត វ្រះកម្រតេង៑ អញ៑ សកវ្រហ្ម លិះ២ ប្រតិទិន បាទមូល ត

១០. អ្នោវ ភូមិ សស្តា ឆោក ខ្វាជារ៑ បិ ដោ វាបិ ប្រៀ វាបិ[គិ] វទេវ វាបិ ហរី

១១. ទេវ បរិចារ វាបិ អាទិត្យ គ្រាមបាល វាបិ មាធវ គ្រាមបាល វាបិ គិ

១២. វ គណ្ណ វាបិ សិរ៑ វាបិ សេ វាបិ ឆោគបាល វាបិ អាត៑ វាបិ ចន្ទ្រ វាបិ ញ

១៣. វាបិ អម្ឫត ខ្ញោញ៑ វល វាបិ គុរុន វាបិ វ្រហ្ម តំម្រ ទ្វង៑ តំល្វង៑ វាបិ នន

១៤. យ ថ្នាំផ្ទុះ វាបិ អបិ ថ្នាំ ផ្ទុះ

អត្ថបទដោយៈ កំ វណ្ណារ៉ា

AMS អរិយធម៌ខ្មែរ KHMER CIVILIZATION

**បំណកប្រែ**

(បន្ទាត់ទី១ ដល់ទី៣) ឆ្នាំ ៨៩១ មហាសករាជ ៤កើត ខែស្រាពណ៍ ថ្ងៃសៅរ៍ ម្រតេញម្នាក់មានឈ្មោះថា "ណិរន្តពចាយ៌្យ" ដែលជាខ្លោញក្មំ (អធិកាបតីទេវស្ថាន) កម្រតេង ជគត លិង្គបុរ បានដាវដីភូមិព្រៃត្រពាំងខ្សាច់។

(បន្ទាត់ទី៣ ដល់ទី១២) ដោយសង្កតិ គិតចាប់ពីទិសបូព៌ (ខាងកើត) អស់ព្រៃចន្ទូរ រំព្យក (ព្រៃចង្អូររំចេក) ព្រៃ សស្ដា ស្ទឹងតោកខ្វា ដោយឡើងទៅរហូតដល់ព្រៃចាស់និងស្ទឹងជារ ឡើងទៅរហូតដល់ព្រៃចាស់នូវគ្នងជារ ដែលខាងកើតប្រសព្វនឹងស្ទឹងល្បៀង។ ដីដែលបានជាវ និងភាជន៍ ពីព្រះគម្តែង អញ ជាម្ចាស់ (ព្រះកម្រតេង អញ តពជ្យ) និងព្រះកម្រតេង អញ សកព្រាហ្មណ៍ ជន (ទំងន់) ៧ ជ្យង ធ្វើពិធីបូជា ដល់ព្រះកម្រតេង អញ សុវណ្ណ ឱ្យយ័ញ្ញ ដល់ព្រះកម្រតេង អញ តពជ្យ ចំនួន២លិះ ដល់ព្រះកម្រតេង អញ សកព្រាហ្មណ៍ ចំនួន២លិះជាប្រចាំថ្ងៃ។ សម្រាប់បាទមូល (អធិការបតិ) ភូមិ សស្ដា,តោក ខ្វាជារ ដើម្បីជាវ វាប ជ្រៀ វាប គិរទេវ វាប ហរី ជា ទេវបរិចារ (អ្នកបម្រើព្រះ) វាប អាទិត្យ គ្រាមបាល វាប មាធវ គ្រាមបាល វាប សិវ គណ្ឌ វាប សិរ វាប សេ វាប គោគបាល វាប អាត វាប ចន្ទ្រ វាប ញ វាប អម្ឫត ខ្លោញ វល (តម្រួចពល) វាប គុរុន វាប ព្រហ្ម តំម្រ (ដំរី) ទ្វង តំល្វង វាប ននយ ថ្នាំផ្ទុះ (អ្នកធ្វើពិធីជម្រះបាប) វាប អប ថ្នាំផ្ទុះ (អ្នកធ្វើពិធីជម្រះបាប)។

ជារួមមក សិលាចារឹកប្រាសាទខ្នារ K.1312 បានផ្ដល់ព័ត៌មានជាច្រើនអំពីការជាវដីព្រៃសម្រាប់ធ្វើជាមូលនិធិផ្គត់ផ្គង់ដល់ប្រាសាទ ដែលដីដែលបានជាវនោះ គឺព្រាហ្មណ៍ម្នាក់ដែលជាអ្នកទទួលបន្ទុកបានកំណត់ព្រំប្រទល់យ៉ាងជាក់លាក់។

**ឯកសារយោង**

Coedès, G. 1966. *Inscription du Cambodge,* Vol. 8, Hanoi.

អត្ថបទដោយ៖ កំ វណ្ណាវ៉ា



រូបលេខ១៖ ប្រាសាទខ្នារ ខេត្តព្រះវិហារ

អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ កំ វណ្ណាក់



រូបលេខ២៖ ប្រាសាទខ្នារ ខេត្តព្រះវិហារ

អត្ថបទដោយ៖ កំ វណ្ណាក់



រូបលេខ៣៖ សិលាចារឹកនៅជាប់នឹងមេទ្វារប្រាសាទខ្នារ ចុះបញ្ជីលេខ K.1312

អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ កំ វណ្ណាក់



អរិយធម៌ខ្មែរ KHMER CIVILIZATION

រូបលេខ4៖ ក្រដាសផ្តាមសិលាចារឹកប្រាសាទខ្នារ K.1312 (ផ្តិតដោយ៖ កំ វណ្ណារ៉ា)

អត្ថបទដោយ៖ កំ វណ្ណារ៉ា